# ការសំភាសន៍របស់ សេង ពិសី

**កៈ អ្នកដែលសំភាសន៍ឈ្មោះ សេង ពិសី     ខៈ អ្នកដែលត្រូវសំភាសន៍ឈ្មោះ Matt Boyd**

កៈ Okay អញ្ចឹងថ្ងៃហ្នឹង ថ្ងៃទី២៥ ខែ៩ នៅជិតបុសក្រលា នៅកំពង់ចាម។ ហើយខ្ញុំឈ្មោះ Matt Boyd ខ្ញុំសម្ភាសន៍បងស្រី។ ឈ្មោះពេញរបស់បង់ស្រីឈ្មោះអីដែរ?

ខៈ សេង ពិសី។

កៈ សេង ពិសី។ ហើយបងស្រី ស្រុកកំណើតនៅណាដែរ?

ខៈ ខ្ញុំនៅខេត្តកំពង់ចាម ប៉ុន្តែនៅខាងភូមិទី១៩។

កៈ Ok ហើយដឹងពី ថ្ងៃខែកំណើត?

ខៈ ដឹងដែរ។ ថ្ងៃខែកំណើតខ្ញុំ? ថ្ងៃ១៨ ខែកក្កដា ឆ្នាំ១៩៨៥។

កៈ ៨៥។ ហើយ អញ្ចឹងឥឡូវ អាយុ ៣១។

ខៈ ហ្នឹងហើយ ជិត ៣១។ ខែកក្កដាវិញ ៣១។

កៈ ហើយ ឈ្មោះម៉ាក់ប៉ាឈ្មោះអីដែរ?

ខៈ ម៉ាក់ខ្ញុំ គាត់ឈ្មោះ អ៊ុក សិផានី គាត់ជាគ្រូបង្រៀន ហើយប៉ាខ្ញុំឈ្មោះ សេង ឡុង គ្រូបង្រៀនដែរ។

កៈ គ្រូបង្រៀនអីដែរ?

ខៈ ម៉ាក់ខ្ញុំគ្រូបង្រៀនបឋម សាលាបឋមសិក្សា។ ក៏ប៉ុន្តែ ប៉ាគាត់វិទ្យាល័យ គ្រូបង្រៀនវិទ្យាល័យ។

កៈ ដូចជាគ្រូ...

ខ៖ Math.

ក៖ ដូចជា… Oh, Math! គណិតវិទ្យាជា។ អញ្ចឹងបងស្រីពូកែខាងគណិតវិទ្យា។

ខ៖ [សើច] អត់ទេ អត់សូវ។

ក៖ ហើយចុះស្គាល់ឈ្មោះតាយាយ?

ខ៖ ស្គាល់ដែរ។

ក៖ គាត់ឈ្មោះអីដែរ?

ខ៖ ជីដូនរបស់ខ្ញុំ គាត់ឈ្មោះ ម៉ន សំណាង។ លោកតាឈ្មោះ អ៊ុក សុខន។

ក៖ ខាងប៉ា ឬក៏ខាងម៉ាក់?

ខ៖ ខាងម្ដាយ។ ខាងម៉ាក់។

ក៖ តែខាងប៉ាស្គាល់អត់?

ខ៖ អត់ស្គាល់សោះ។

ក៖ ចុះតាទួតយាយទួតស្គាល់អត់?

ខ៖ អូ… លោកតាទួត គាត់ឈ្មោះ ម៉ន ណៃ ម៉ាក់យាយគាត់ឈ្មោះ ភ្លេចបាត់ហើយ។

ក៖ Okay. ហើយជំនាន់មួយទៀតអត់ស្គាល់? អត់អីទេ ល្អហើយ។ ស្គាល់គេច្រើន។ អញ្ចឹងធំឡើងនៅណាដែរ?

ខ៖ ធំឡើងនៅ... កន្លែងដែលខ្ញុំធំឡើង គឺជាមួយនឹងកន្លែងដែលខ្ញុំកើត។ តាមពិតទៅពេលខ្ញុំកើត ខ្ញុំកើតនៅភ្នំពេញទេ ប៉ុន្តែពេលដែលខ្ញុំចាប់ផ្ដើមពីអាយុ៥ឆ្នាំខ្ញុំរស់នៅកំពង់ចាម។

ក៖ Oh អញ្ចឹង? នៅម្ដុំណា នៅភ្នំពេញ?

ខ៖ នៅភ្នំពេញ នៅឫស្សីកែវ។ គីឡូលេខ៦។

ក៖ Okay ជិតវត្តភ្នំ?

ខ៖ អត់ទេ! ឆ្ងាយ ចេញពីក្រុង...

ក៖ ហួសស្ពានជ្រោយចង្វារ?

ខ៖ ហ្នឹងហើយ ទៅពីស្ពានជ្រោយចង្វារឈិន ទៅច្រើនគីឡូដែរ។

ក៖ អីចឹងមក... អីចឹងកើតនៅភ្នំពេញមកនេះ បងដូចជាយ៉ាងម៉េចដែរ? ដូចជាចូលចិត្តឬក៏អត់សូវចូលចិត្ត?

ខ៖ ពេលហ្នឹង អាយុប៉ុណ្ណឹង ប្រហែល ជាអត់សូវគិតបានប៉ុន្មានព្រោះនៅក្មេង សំខាន់រត់លេងហើយរៀន។ អត់សូវខ្វល់ខ្វាយថាការផ្លាស់ប្តូរទីកន្លែងរស់នៅហ្នឹងវាម៉េច។ អត់សូវដឹង។

ក៖ មានមិត្តភក្តិច្រើន។

ខ៖ ហ្នឹងហើយ មានច្រើន ធម្មតាដូចគេ...

ក៖ ហើយអីចឹង ធ្វើអ្វីខ្លះ ដូចជាលេង game អីខ្លះជាមួយមិត្តភក្តិ?

ខ៖ ឆ្នាំជំនាន់ហ្នឹង ដូចមានលេង... លេងអានេះ។ លោតកៅស៊ូ លេងមឹក លេងបាយខុម លេងអីច្រើនទៀត ផ្សេងៗទៀត។ តាមជំនាន់ដែលក្មេងរស់ ជំនាន់ក្មេងដែលគេរស់នៅជំនាន់ហ្នឹង។

ក៖ បាទ។ ហើយចូលសាលារៀន អាយុ៥ឆ្នាំ?

ខ៖ ហ្នឹងហើយ ៥ ឆ្នាំ។

ក៖ ចាំសាលានៅណាដែរ?

ខ៖ សាលាបឋមសិក្សាពាក់សិន។ នៅជិតព្រះវិហារសាខា១។

ក៖ Oh okay. ជិតមាត់ទន្លេ។ ចឹងនិយាយទៅ កុមារភាពដូចម៉េចដែរ? ដូចជាសប្បាយឬក៏ ធុញច្រើន ឬក៏អត់សូវចូលចិត្ត?

ខ៖ និយាយចំទៅ នៅពេលខ្ញុំអាយុ ៥ ឆ្នាំហ្នឹង នៅពេលកុមារភាពអស់ខ្ញុំហ្នឹង វាជាពេលវេលាមួយដែលអត់សូវសប្បាយ។ ប៉ុន្តែវាត្រូវតែសប្បាយ។ ព្រោះហេតុអីបានថា អត់សូវសប្បាយ? ពេលខ្ញុំអាយុ ៥ ឆ្នាំ ហ្នឹងឪពុកម្តាយខ្ញុំក៏បានចែកផ្លូវគ្នាហើយ។ តែគ្រាន់ថា ដូចខ្ញុំនិយាយខាង

ដើម ចឹងក្មេងអត់សូវគិតច្រើន។ ទៅរៀនហើយលេង។ អត់សូវខ្វាយខ្វល់ច្រើន។ ប៉ុន្តែក៏នៅតែមានអារម្មណ៍ថា រាងដូចជាសោកសៅតិចតួចដែរ។

ក៖ បាទ។ ចឹងមានឱកាសជួបម៉ាក់និងប៉ាជាញឹកញាប់អត់?

ខ៖ ម៉ាក់ខ្ញុំមាននៅជាមួយរាល់ថ្ងៃ ប៉ុន្តែប៉ាអត់នៅជាមួយទេ គាត់នៅភ្នំពេញ។

ក៖ Oh អត់សូវជួប។

ខ៖ ហ្នឹងហើយ យូរជួបគ្នាម្តង។ ជួនកាលក៏អត់ជួបទៅ។

ក៖ Oh ហើយមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូនខ្ញុំមាន ៣ នាក់។ ស្រី ២ ប្រុស ១ ខ្ញុំ ជាកូនបង។ បន្ទាប់ខ្ញុំប្រុស ប្អូនពៅស្រី។

ក៖ ហើយនៅជាមួយម៉ាក់ទាំងអស់គ្នា?

ខ៖ ហ្នឹងហើយ ហើយនិងជីដូន ហើយនិងជាមួយម្តាយមីង។ ៤ នៅជាមួយគ្នា… ៦ នាក់ សមាជិកក្នុងគ្រួសារ ៦ នាក់។

ក៖ ហើយដល់ពេល ដូចជាយុវវ័យយ៉ាងម៉េច? ដូចជាពិបាកជាង ឬក៏ដូចជា…

ខ៖ ដូចជានៅដដែល។

ក៖ Okay ពិបាក។ ដោយសារតែអស់ប៉ា ឬក៏ដូចជាមាន…

ខ៖ និយាយទៅ ការរស់នៅមិនសូវជាពិបាកប៉ុន្មានទេ ប៉ុន្តែគ្រាន់ថាគ្រួសារធម្មតាត្រូវបែកបាក់ទៅវាដូចជាខ្វះអីម្យ៉ាងចឹង។ ការរស់នៅមិនសូវជាពិបាកអីណាទេ ប៉ុន្តែគ្រាន់ថាអារម្មណ៍មួយដែលថា គ្រួសារបែកបាក់គឺវាអត់សូវសប្បាយប៉ុន្មានអី។

ក៖ ហើយបងបានចាប់ផ្តើមធ្វើការក្នុងយុវវ័យ… អាយុ ១៥ ឆ្នាំ។

ខ៖ ១៥ ១៦ អត់ទាន់ធ្វើផង រហូតដល់ ១៧ ១៨ ឆ្នាំ។

ក៖ អូ ធ្វើការអីដែរ?

ខ៖ ការងារហ្នឹង គេហៅថា ស្គាល់អាវប៉ាក់អី?

ក៖ អាវប៉ាក់?

ខ៖ ហ្នឹងហើយ។ អាវស្រីនារីខ្មែរចូលចិត្តស្លៀក ហូលផាមួង អាវប៉ាក់ គេឌិនគេប្រើអង្កាំឌិននៅលើអាវប៉ាក់ហ្នឹង។ ហើយខ្ញុំធ្វើអាហ្នឹង។

ក៖ ក្នុងរោងចក្រ?

ខ៖ អត់ទេ។ គេមានហាងរបស់គេ ហើយគេត្រូវការអ្នកឌិន។ ហើយយើង យើងយកខោអាវហ្នឹងទៅធ្វើនៅផ្ទះទៅ ធ្វើរួចយកទៅឲ្យកន្លែងគេ។

ក៖ ចឹងម៉ាក់បង្រៀនឲ្យធ្វើមួយហ្នឹង ឬក៏...

ខ៖ អត់ទេ។ ចេះ ចេះពីខ្លួនឯង។ មើលគេធ្វើទៅមើលទៅចេះដែរ។

ក៖ ចឹងមានដូចជា ដូចជា skill មួយឬក៏ពីរដែលម៉ាក់បានបង្រៀនឲ្យ?

ខ៖ ជំនាញ ហ្នឹងហើយមានខ្លះៗ មានខ្លះ អាហ្នឹងដ៏មានប៉ុនយើងអាចធ្វើបាន។

ក៖ ចឹង គាត់បង្រៀនធ្វើអ្វីខ្លះដែរ?

ខ៖ គាត់ crochet គាត់ប្រើម្ជុលចាក់ សម្រាប់គូរកូនខ្មើយផ្សេងៗទៀត ដែលយើងធ្វើដោយដៃដោយបញ្ចូលមួយហ្នឹង។ ប៉ុន្តែខ្ញុំអត់ចេះប្រើម្ជុលពីរ ចេះព្រមម្ជុលមួយ។

ក៖ អញ្ចឹងបងស្រីទៅរៀន គេហៅថាមហាវិទ្យាល័យ រក៏សាកលវិទ្យាល័យ?

ខ៖ ខ្ញុំបញ្ចប់ត្រឹមវិទ្យាល័យ ពេលហ្នឹងរៀបចំចេញបេសកកម្ម។ ហាត់បានបន្តដល់មហាវិទ្យាល័យអីនៅឡើយ។

ក៖ អាយុ ២១?

ខ៖ ចប់វិទ្យាល័យ ខ្ញុំអាយុត្រឹម១៨ឆ្នាំ... ១៧ ១៨ ឆ្នាំ។ ក៏ប៉ុន្តែពេលហ្នឹងយើងអត់ទាន់មានលុយដើម្បីបង់បម្រើបេសកកម្ម ត្រូវចាំរហូតដល់អាយុ២១។ ហើយធ្វើការក្រៅម៉ោងតិចតួច ចឹងទៅ។

ក៖ បេសកកម្មយ៉ាងម៉េចដែរ?

ខ៖ បេសកកម្ម មានអីល្អ។

ក៖ ទៅបម្រើនៅតំបន់ណាខ្លះ?

ខ៖ បេសកកម្មរបស់ខ្ញុំដំបូងបំផុត ខ្ញុំនៅខាងសន្ធរម៉ុក។ បន្ទាប់មកចេញពីសន្ធរម៉ុកទៅ ទៅខាងតាខ្មៅសាខាទី២ក្នុងបេសកកម្ម បន្ទាប់មកផ្លាស់មកចំការមន។ ហើយមកខាងវត្តភ្នំចប់។ ៤សាខា។

ក៖ ភ្នំពេញទាំងអស់។

ខ៖ ហ្នឹងហើយ។ អត់ទេ នៅតាខ្មៅមួយដែរ។ បាននៅខ្មៅមួយ។

ក៖ នៅសម័យនោះ អត់ទាន់មានស៊ីស្ទើរនៅបាត់ដំបងនិងសៀរាប?

ខ៖ មានហើយ។

ក៖ អូ មាន?

ខ៖ សៀមរាបអត់ទាន់បើក តំបន់សៀមរាបអត់ទាន់បើក។ សៀមរាប ថ្ងៃដែលខ្ញុំនៅ Mission Home ថ្ងៃបញ្ចប់បេសកកម្មហ្នឹង គេចាប់ផ្តើមបើកតំបន់សៀមរាប។ [សើច]

ក៖ Oh អ៊ែលឌើរ ម៉ាស្ទើរ ទៅពេលបើក។

ខ៖ ហ្នឹងហើយ។

ក៖ ចឹង មានរៀនអ្វីខ្លះក្នុងបេសកកម្ម?

ខ៖ រៀនភាសា ប៉ុន្តែអត់ជោគជ័យ។ អត់សូវបានល្អប៉ុន្មាន។ ដោយសារនិយាយទៅ អត់ដឹងថាបញ្ហាអី ប៉ុន្តែព្យាយាមដែរ ប៉ុន្តែវាអត់ជោគជ័យ។

ក៖ អញ្ចឹងដឹងច្បាស់ដែរ។ មានរៀនអីទៀតក្នុងបេសកកម្ម ដូចជាការអត់ធ្មត់ ឬក៏...?

ខ៖ និយាយពីរឿងហ្នឹង ហ្នឹងហើយច្រើន ការគ្រប់គ្រង ពេលវេលា ការបង្រៀន ការបន្ទាបខ្លួន ភាពអត់ធ្មត់អី យើងរៀនដែរ។ ហើយបេសកកម្មគឺជាពេលដែលផ្លាស់ប្តូរយើង។ ខ្ញុំបានរៀនច្រើន។

ក៖ មានដូចជារឿងមួយដ៏អស្ចារ្យក្នុងបេសកកម្ម?

ខ៖ មានមួយដែរ។ រឿងហ្នឹង ពេលដែលខ្ញុំនៅចំការមន មានកូនស្រីម្នាក់ អាយុប្រហែលជា ១២ ឆ្នាំ។ កូនហ្នឹង អ្នកស្រុកអ្នកភូមិគិតថាគាត់ប្រហែលជាមិនមានឱកាសដើរម្តងទៀតទេ។ ព្រោះគាត់ឈឺរយៈពេលយូរ។ ហើយពេលគាត់ដើរ គាត់ដើរដូចពាក់កណ្តាលអង្គុយ។ មានន័យថាអង្គុយទៅដើរទៅម៉ង។ ហើយថ្ងៃមួយមានពីណាណែនាំកូនស្រីហ្នឹងឲ្យខ្ញុំស្គាល់។ ដល់ពេលខ្ញុំទៅជួបជាមួយនឹងដៃគូរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍មួយថា ដូចជា ចង់ឱ្យអែលឌើរនឹងប្រសិទ្ធិពរឲ្យគាត់។ ប៉ុន្តែយើងត្រូវសុំការអនុញ្ញាតពីឪពុកម្តាយគេសិន។ ហើយសួរការអនុញ្ញាត ពីសាមីខ្លួនសិន។ ហើយជីដូនរបស់គេ គាត់សប្បាយចិត្ត គាត់ថាបើសិនជាអាចមានអ្វីធ្វើឱ្យកូនគាត់ផ្លាស់ប្តូរ គាត់សុខចិត្តថា សឹងតែឲ្យកូនរបស់គាត់ហ្នឹងថ្វាយម៉ង។ ខ្ញុំថា អត់ដល់ប៉ុណ្ណឹង ប៉ុន្តែគ្រាន់ថាខ្ញុំគ្រាន់តែមានអារម្មណ៍មួយថាបំផុសថា ខ្ញុំចង់ឲ្យមានការប្រសិទ្ធិពរមួយចឹងណាស់។ បន្ទាប់មកសុំការអនុញ្ញាតហើយ ប្រហែលជាសប្តាហ៍ក្រោយ អែលឌើរគាត់ចាប់ផ្តើមប្រសិទ្ធិពរ។ ហើយពេលដែលគាត់ប្រសិទ្ធពរហើយ ខ្ញុំមានការបំផុសមួយទៀតថា ចង់ឲ្យសមាជិកនៅក្នុងផ្ទះហ្នឹងជួយគាត់រៀនដើរឬមួយក៏ម៉ាស្សាធ្វើសរសៃគាត់ពេលព្រឹក អីចឹង។ ហើយអ្នកនៅក្នុងគ្រួសារគាត់ហ្នឹង គាត់ចាប់ផ្តើមធ្វើអីចឹង។ នៅពេលប្រហែលជា២... ផុត២ខែយ៉ាងយូរ កូនម្នាក់ហ្នឹង... អូ! អត់ទាន់ដល់ពេលហ្នឹង ខ្ញុំសុំត្រឡប់ទៅក្រោយបន្តិច។ មានពេលមួយនោះ មានសន្និសីទ កំឡុងពេលដែលគាត់រៀនដើរនហ្នឹង មានសន្និសីទទូទៅមួយ។ ហើយថ្ងៃហ្នឹងខ្ញុំអញ្ជើញគាត់មកចូលរួម អញ្ជើញ២ទៅ៣ដង។ គាត់ព្រមមក ទៀតទាន់ដល់ពេលសន្និសីទហ្នឹង។ ហើយខ្ញុំចាប់ផ្តើមយល់ថា ប្រហែលជាគាត់មានអារម្មណ៍អៀនខខ្មាស់ព្រោះថា ការដើររបស់គាត់ខុសពីយើង។ យើងដើរឈរ តែគាត់ដើរអង្គុយ។ តែវាអស្ចារ្យដែលគាត់ព្រមមក។ ហើយខ្ញុំដឹកដៃគាត់ដើរកាត់ហ្វូងមនុស្សច្រើនមែនទែន រាប់រយនាក់។ ដល់ពេលសន្និសីទ ហើយគាត់ក៏ចាប់ផ្តើមបន្តហាត់រៀនដើរធម្មតា។ អ្វីដែលចម្លែកហ្នឹង ពេលដែលខ្ញុំ... ពេលហ្នឹងមានការផ្លាស់ប្តូរ transfer ។ ខ្ញុំបានប្តូរចេញពីតំបន់ហ្នឹង ហើយខ្ញុំព្យាយាមសួរដល់អ្នកផ្សព្វផ្សាយសាសនាដែលនៅក្នុងតំបន់ហ្នឹង។ ក្រោយមកគេថា ស្រីមាសអាចដើរបានហើយ គាត់អាចដើរបាន។

កៈ តែឈរ?

ខៈ តែឈរ។ ប៉ុន្តែគាត់ឈឺយូរណាស់ គាត់គេងលើកន្ទេលហ្នឹង ប្រហែលជាប្រាំមួយ ប្រាំពីរឆ្នាំ អត់ងើបទាល់តែសោះ។ ហើយក៏អត់មានគ្រូពេទ្យណាមួយព្យាបាលគាត់ដែរ។ ហើយក្រុមគ្រួសារគាត ភ្ញាក់ផ្អើលខ្លាំងមែនទែន ហើយមួយហ្នឹង ខ្ញុំបានយល់ច្រើន ខ្ញុំយល់អំពីអំណាចនៃបព្វជិតភាព ខ្ញុំយល់អំពីអារម្មណ៍សេចក្ដីស្រលាញ់របស់ព្រះបិតាសួរ។ ហើយវាជាអព្ភូតហេតុមួយអស្ចារ្យបំផុត។ រឿងដែលខ្ញុំចាំនៅក្នុងបេសកកម្មរបស់ខ្ញុំក្នុងចំណោមរឿងផ្សេងៗទៀត។

កៈ ហើយ ចឹងបងប្រុសសរិន ជួបគាត់ដំបូងនៅកន្លែងណាដែរ?

ខៈ ពេលហ្នឹងសមាជិកដូចគ្នា នៅសាខា១។

កៈ នៅកំពង់ចាម។

ខៈ ហ្នឹងហើយ គេអត់ទាន់បំបែកសាខា ពីមុនមានតែសាខា១និងសាខា២។ ហើយផ្ទះរបស់គាត់ហ្នឹង គឺនៅក្នុងតំបន់សីខា១ដែរ។ ចឹងយើងអត់ទាន់បែងចែកតំបន់ យើងមានឱកាសស្គាល់គ្នា។

កៈ ហើយ មានបំណងចង់ធ្វើសង្សារគាត់មុនចេញជាស៊ីស្ទើរ?

ខៈ អត់។ [សើច] អត់សោះ។

កៈ ដូចជាអត់ចូលចិត្តគាត់?

ខៈ អត់ចូលចិត្តអី។ [សើចទាំងពីរ]

កៈ អញ្ចឹងចប់បេសកកម្មរួយហើយ គឺជាចាប់ផ្ដើមចូលចិត្តគាត់ ឬក៏ម៉េចដែរ?

ខៈ ប្រហែលជាពេលហ្នឹង។ បន្ទាប់ពីចប់បេសកកម្ម ព្រោះពេលនៅសមាជិកខ្ញុំអត់ដែលមានអារម្មណ៍ថាចូលចិត្តគាត់។ អត់ចូលចិត្តផងគ្រាន់ធម្មតា ស្គាល់គ្នាធម្មតាៗ ដូចយុវជនយុវនារីទូទៅ។

កៈ បាទ។

ខ៖ ហើយក៏អត់ដឹងថា គាត់ហ្នឹងស្រឡាញ់ឬមួយក៏អត់ ខ្ញុំអត់ដឹងអី ព្រោះខ្ញុំ ពេលហ្នឹងមានមិត្តភ័ក្តិរបស់ខ្ញុំដែរ។ ខ្ញុំមានពេលវេលា មានមិត្តភ័ក្តិ មានកន្លែងរបស់ខ្ញុំដែរ អត់សូវមានទំនាក់ទំនងជាមួយគាត់ច្រើន។

ក៖ អញ្ចឹងចប់បេសកកម្មរួចហើយ មានប្រហែលជាប៉ុន្មានឆ្នាំទាល់តែចាប់ផ្តើម ដូចជា date គាត់?

ខ៖ ប្រហែលជា ៦ខែជាង ៦ ៧ ខែ។

ក៖ ហើយ ភ្ជាប់ពាក្យ ដូចជាយូរឬក៏ ទាល់តែយូរបានភ្ជាប់ពាក្យ?

ខ៖ ខ្ញុំអត់បានភ្ជាប់ពាក្យយូរផង។ ការម៉ង។ [សើច]

ក៖ ការហ្នឹង ឆ្នាំទីប៉ុន្មានដែរ?

ខ៖ ២០០៨។

ក៖ '០៨។ ហើយគាត់ឡើងជាប្រធានសាខា ២០០៩។

ខ៖ ហ្នឹងហើយ។ ពេលនោះ សេដា អាយុប្រហែលជា ៩ ខែ។

ក៖ Okay ចឹងក្នុងជីវិតរបស់បងស្រី មានពេលណាដែល ដូចជាសប្បាយរីករាយជាងគេ? បទពិសោធន៍មួយដែលសប្បាយជាងគេក្នុងជីវិត?

ខ៖ ទី១ ពេលវេលាក្នុងបេសកកម្មរបស់ខ្ញុំ។ ទី២ គ្រួសារដែលយើង ពេលដែលយើងនៅជាមួយគ្នាមានកូនៗ ពួកគេមានសុខភាពល្អ ហើយស្នាមញញឹម។ ហ្នឹងជាពេលដែលរីករាយបំផុត។

ក៖ ចុះបើនិយាយពីបទពិសោធដែលពិបាកជាងគេក្នុងជីវិត។

ខ៖ ប្រហែលជាពេលនៅក្មេង។

ក៖ ដោយសារតែនឹកប៉ា។ ចឹង ខ្ញុំដឹងថា នៅថ្ងៃអនាគត ដូច៥០០ឆ្នាំ កូនរបស់បងស្រីនិងមានឱកាសស្តាប់សំឡេង បងស្រីថ្ងៃនេះ។ ចង់សួរថា តើមានពាក្យសម្តី មានសារចង់និយាយទៅគាត់? ដូចនៅ៥០០ឆ្នាំនៅថ្ងៃអនាគត?

ខ៖ [សើច] អឺ... សារដែលខ្ញុំចង់និយាយគឺថា អ្វីដែលខ្ញុំចង់ឃើញ គឺឃើញពួកគេដើរនៅក្នុងដំណើងល្អ។ ព្រោះថានៅពេលដែលពួកគេនៅតែស្មោះត្រង់ចំពោះដំណើងល្អ គេនឹងក្លាយជាកូនល្អនៅក្នុងក្រុមគ្រួសារ ប្រជាពលរដ្ឋល្អនៅក្នុងសង្គម ហើយធ្វើជាប្រជាជនដែលផ្តល់ផលប្រយោជន៍ដល់សង្គម ដល់ប្រទេ ស ដល់សាសនាចក្រ។

ក៖ ល្អ។ មានអីទៀតចង់និយាយ ចង់អភិរក្ស ដូចជាសាច់រឿង១ ឬក៏បទពិសោធន៍១ មានអីទៀតចង់អភិរក្ស?

ខ៖ ដូចជា និយាយអី? [សើច]

ក៖ Ok! អត់អី។ អរគុណច្រើន ហើយអស់សំណួរហើយ។

ខ៖ អត់អី ចាំ អរគុណដូចគ្នា។